## ដែនទឹកផ្ទៃក្នុង (internal water)

ដែនទឹកផ្ទៃក្នុងគឺជាដែនទឹកដែលនៅក្តោបដោយខ្សែបន្ទាត់មូលដ្ឋានលាតសន្ធឹងទៅរកឆ្នេរគោករបស់រដ្ឋ។ដែនទឹកផ្ទៃក្នុងមានពីរប្រភេទ៖ ដែនទឹកផ្ទៃក្នុងធម្មតា និងដែនទឹកផ្ទៃក្នុងប្រជុំកោះ (archipelagic internal water)។

**មាត្រា៨នៃអនុសញ្ញា** UNCLoS **ឆ្នាំ១៩៨២ ចែងថា៖**

១. លើកលែងតែមានចែងក្នុង**ជំពូកទី៤** ផ្ទៃទឹកទៅខាងដីគោកនៃខ្សែបន្ទាត់មូលដ្ឋាននៃសមុទ្រដែនដីគឺជាផ្នែកនៃដែនទឹកផ្ទៃក្នុងរបស់រដ្ឋ។

២. ក្នុងករណីដែលការកំណត់ខ្សែបន្ទាត់មូលដ្ឋានត្រង់ ដោយអនុលោមតាមវិធីសាស្ត្រដូចមានចែងក្នុងមាត្រា៧ មានអានុភាពបង្កើតជាតំបន់ដែនទឹកផ្ទៃក្នុង ដែលពីមុនមិនត្រូវបានចាត់ទុកបែបនេះ សិទ្ធិឆ្លងកាត់ដោយមិនបំពានដូចមានចែងក្នុងអនុសញ្ញានេះ នៅតែមានអត្ថិភាពក្នុងដែនទឹកនោះ។

( Except as provided in Part IV, waters on the landward side of the baseline of the territorial sea form part of the internal waters of the State. 2. Where the establishment of a straight baseline in accordance with the method set forth in article 7 has the effect of enclosing as internal waters areas which had not previously been considered as such, a right of innocent passage as provided in this Convention shall exist in those waters)

- ដែនទឹកផ្ទៃក្នុងនេះ ត្រូវបានចាត់ទុកដូចជាដែនដីរបស់រដ្ឋ។

- រដ្ឋមានអធិបតេយ្យពេញលេញ ពោលគឺមានអំណាចពេញទីក្នុង ការអនុវត្តច្បាប់ជាតិរបស់ខ្លួនលើសកម្មភាពនានានៅដែនទឹកនេះ។ អធិបតេយ្យរបស់រដ្ឋជាប់ឆ្នេរលើដែន ទឹកផ្ទៃក្នុង ទាំងលើដី ក្រោមដី និងលើអាកាសផង។

- រដ្ឋជាប់ឆ្នេរត្រូវធានានូវសុវត្ថិភាពនាវាចរក្នុងផៃរបស់ខ្លួន។

-រដ្ឋដទៃមានសិទ្ធិធ្វើដំណើរចូលឬឆ្លងកាត់តំបន់នេះប្រសិនបើមានការយល់ព្រមពីរដ្ឋជាប់សមុទ្រ។

- នាវាបរទេស មិនមានសិទ្ធិឆ្លងកាត់ដោយមិនបំពានទេ លើកលែងតែការឆ្លងកាត់ប្រភេទនេះជាវិធានទំនៀមទម្លាប់អន្តរជាតិឬមានសន្ធិសញ្ញាណាមួយអនុញ្ញាត។ (មាត្រា៨.២ នៃ **UNCLoS)**

*-**ខ្សែបន្ទាត់មូលដ្ឋានមានបីប្រភេទ៖*** ខ្សែបន្ទាត់មូលដ្ឋានធម្មតា, ខ្សែបន្ទាត់មូលដ្ឋានត្រង់, ខ្សែបន្ទាត់មូលដ្ឋានប្រជុំកោះ។ **មាត្រា ៥ (ខ្សែបន្ទាត់មូលដ្ឋានធម្មតា)៖** លើកលែងតែមានចែងផ្ទុយក្នុងអនុសញ្ញានេះ ខ្សែបន្ទាត់មូលដ្ឋានធម្មតាសម្រាប់វាស់ប្រវែងទទឹងនៃសមុទ្រដែនដីគឺខ្សែបន្ទាត់ទឹកនាចនៅតាមបណ្តោយឆ្នេរសមុទ្រ ដូចដែលមានគូសនៅលើផែនទីសមុទ្រខ្នាតធំដែលត្រូវបានទទួលស្គាល់ជាផ្លូវការដោយរដ្ឋជាប់ឆ្នេរសមុទ្រ។